ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ : ១៤៣៥ អយក.ប្រក

# ប្រកាស

## ស្តីពី

## លក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យលម្អិត សម្រាប់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង អប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- យោងតាមការចាំបាច់ របស់ក្រសួង អប់រំ យុវជន និងកីឡា



អាស័យដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ៤២៧ ៣៨៦ / ៤២៦ ៩៥១ / ២១២ ៥១២
E-mail: crsmeys@camnet.com.kh / yangyano@camnet.com.kh Web Site: www.moeys.gov.kh

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

ប្រការ ១

ប្រកាសនេះ មានគោលដៅកំណត់ អំពីលក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យលម្អិត សម្រាប់ការបង្កើតគ្រឹះស្ថាន-ឧត្តមសិក្សាទាំងសាធារណៈ និងឯកជន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ២

នីតិបុគ្គលសាធារណៈ នីតិបុគ្គលឯកជន និង/ឬ រូបវន្តបុគ្គល មានសិទ្ធិស្នើសុំបង្កើត គ្រឹះស្ថានឧត្តមសិក្សា ។

ប្រការ ៣

គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានច្បាប់អនុញ្ញាតជាមុន ទើបមានសិទ្ធិជ្រើសរើសនិស្សិត និងដំណើរការបាន ។

## ជំពូកទី ២
## លក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យលម្អិត សម្រាប់ការបង្កើតគ្រឹះស្ថានឧត្តមសិក្សា
### ផ្នែកទី ១
### លក្ខខណ្ឌទូទៅ

ប្រការ ៤

នីតិបុគ្គលសាធារណៈ នីតិបុគ្គលឯកជន និង/ឬ រូបវន្តបុគ្គល ដែលមានបំណងចង់បង្កើត គ្រឹះស្ថានឧត្តមសិក្សា ត្រូវគោរព និងបំពេញឱ្យបាននូវលក្ខខណ្ឌដូចខាងក្រោម ÷

- ការកំណត់ឈ្មោះ និមិត្តសញ្ញា និងប្រភេទ នៃគ្រឹះស្ថានឧត្តមសិក្សា
- ការកំណត់បេសសកកម្ម របស់គ្រឹះស្ថានឧត្តមសិក្សា
- ការរៀបចំអភិបាលកិច្ច និងការគ្រប់គ្រង
- ការរៀបចំកម្មវិធីសិក្សា និងការបង្រៀន
- ការរៀបចំបុគ្គលិករដ្ឋបាល និងបុគ្គលិកបង្រៀន
- ការរៀបចំទីតាំង អគារ និងមូលដ្ឋានសំភារៈរូបវ័ន្ត
- ការរៀបចំផែនការយុទ្ធសាស្ត្រ និងហិរញ្ញវត្ថុ ។

### ផ្នែកទី ២
### ឈ្មោះ និមិត្តសញ្ញា និងប្រភេទ នៃគ្រឹះស្ថានឧត្តមសិក្សា

ប្រការ ៥

ត្រូវកំណត់ឈ្មោះគ្រឹះស្ថានឧត្តមសិក្សា ឱ្យបានច្បាស់លាស់ និងមិនត្រូវឱ្យត្រួត ឬយកតាមឈ្មោះ នៃគ្រឹះ-ស្ថានសិក្សា ឬស្ថាប័នដទៃឡើយ ។

ប្រការ ៦

ត្រូវកំណត់និមិត្តសញ្ញា ឱ្យបានច្បាស់លាស់ និងមិនត្រូវឱ្យដូច ឬប្រហាក់ប្រហែល ឬយកតាមនិមិត្តសញ្ញា នៃគ្រឹះស្ថានសិក្សា ឬ ស្ថាប័នដទៃទៀយ ។

ប្រការ ៧

ត្រូវកំណត់ប្រភេទ នៃគ្រឹះស្ថានឧត្តមសិក្សា ឱ្យបានត្រឹមត្រូវ ដោយអនុលោមតាមអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ ។

## ផ្នែកទី ៣

## បេសកកម្ម

ប្រការ ៨

ត្រូវកំណត់បេសកកម្ម ឱ្យបានច្បាស់លាស់ និងសមស្រប សម្រាប់ការអភិវឌ្ឍធនធានមនុស្ស ប្រកបដោយចំណេះដឹង ចំណេះធ្វើ និង សីលធម៌ ។ បេសកកម្មនេះ ត្រូវផ្សារភ្ជាប់ទៅនឹង ប្រភេទនៃគ្រឹះស្ថានឧត្តមសិក្សា ការអភិវឌ្ឍសង្គមកម្ពុជា តម្រូវការនៃទីផ្សារការងារ និង ការថែរក្សា និងការលើកស្ទួយ នូវវប្បធម៌ ព្រមទាំងអត្តសញ្ញាណជាតិ ។

## ផ្នែកទី ៤

## អភិបាលកិច្ច និងការគ្រប់គ្រង

ប្រការ ៩

គ្រឹះស្ថានឧត្តមសិក្សា មានពីរប្រភេទ គឺ សាកលវិទ្យាល័យ និងវិទ្យាស្ថាន ។ រចនាសម្ព័ន្ធអប់រំ នៃសាកល-វិទ្យាល័យ ត្រូវមានមហាវិទ្យាល័យ និងដេប៉ាតឺម៉ង់ ដែលចំណុះឱ្យមហាវិទ្យាល័យនីមួយៗ ។ មហាវិទ្យាល័យមួយត្រូវមាន ដេប៉ាតឺម៉ង់យ៉ាងតិចបី ( ០៣ ) ។ វិទ្យាស្ថាន ជាការប្រមូលផ្តុំ ផ្នែកឯកទេសមួយ ឬច្រើន ។

ប្រការ ១០

គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានការិយាល័យ ឬផ្នែកមួយចំនួន ដើម្បីធានា ដល់ដំណើរការនៃការងារដូចខាងក្រោម ៖

- រដ្ឋបាល និងបុគ្គលិក
- ផែនការ និងហិរញ្ញវត្ថុ
- ការសិក្សា និងកិច្ចការនិស្សិត
- ការស្រាវជ្រាវ និងការផ្សព្វផ្សាយ
- សហប្រតិបត្តិការ និង
- ការងារផ្សេងទៀត ស្របតាមតម្រូវការ របស់គ្រឹះស្ថានឧត្តមសិក្សា ។

## ប្រការ ១១

គ្រឹះស្ថានឧត្តមសិក្សា ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ (០១) ។ ចំពោះគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ការរៀបចំក្រុមប្រឹក្សាភិបាល ត្រូវគោរពតាមព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ។ ការរៀបចំក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានឧត្តមសិក្សាឯកជន ដែលទើបបង្កើតថ្មី ត្រូវមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។ ក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានឧត្តមសិក្សាឯកជន ត្រូវមានសមាជិកយ៉ាងតិចប្រាំ (០៥) រូប ដែលមានសមាសភាពចាំបាច់ដូចខាងក្រោម ÷

- ម្ចាស់ភាគហ៊ុន ឬតំណាង
- តំណាងបុគ្គលិក/សាស្ត្រាចារ្យ
- ឥស្សរជន ដែលមានចំណេះដឹងកម្រិតឧត្តមសិក្សា និងមានបទពិសោធន៍ក្នុងការងារគ្រប់គ្រង ។

ក្នុងករណីដែល ក្រុមប្រឹក្សាភិបាល មានការផ្លាស់ប្តូរសមាសភាព ប្រធានក្រុមប្រឹក្សាភិបាល ត្រូវផ្តល់ព័ត៌មាន មកក្រសួងអប់រំ យុវជន និងកីឡា ។

## ប្រការ ១២

គ្រឹះស្ថានឧត្តមសិក្សា ត្រូវគ្រប់គ្រងដោយ សាកលវិទ្យាធិការ ឬនាយកមួយរូប និងសាកលវិទ្យាធិការរង ឬនាយករងមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

មហាវិទ្យាល័យ ត្រូវគ្រប់គ្រងដោយ ព្រឹទ្ធបុរសមួយរូប និងព្រឹទ្ធបុរសរងមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

ដេប៉ាតឺម៉ង់ ឬការិយាល័យ ឬផ្នែក ត្រូវដឹកនាំដោយ ប្រធានមួយរូប និងអនុប្រធានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

## ប្រការ ១៣

ការតែងតាំងមន្ត្រីគ្រប់លំដាប់ថ្នាក់ នៃគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ត្រូវគោរពតាម ច្បាប់សហលក្ខន្តិកៈ នៃមន្ត្រីរាជការស៊ីវិល និង/ឬ គោលការណ៍កំណត់ របស់រាជរដ្ឋាភិបាល ។

## ប្រការ ១៤

សាកលវិទ្យាធិការ ឬនាយក នៃគ្រឹះស្ថានឧត្តមសិក្សាឯកជន ត្រូវតែងតាំងដោយក្រុមប្រឹក្សាភិបាល និងផ្ញើរបញ្ជីឈ្មោះមកក្រសួងអប់រំ យុវជន និងកីឡា ដើម្បីជ្រាបជាព័ត៌មាន ។ បុគ្គលិកគ្រប់គ្រងលំដាប់ផ្សេងទៀតនៃគ្រឹះស្ថានឧត្តមសិក្សាឯកជន ត្រូវតែងតាំងដោយ សាកលវិទ្យាធិការ ឬ នាយក និងមានការឯកភាពពីក្រុមប្រឹក្សាភិបាល ។ ការតែងតាំងខាងលើនេះ ត្រូវឱ្យស្របតាមវិធានផ្ទៃក្នុង របស់គ្រឹះស្ថានឧត្តមសិក្សានោះ ។

## ប្រការ ១៥

បុគ្គលិកគ្រប់គ្រងនៃគ្រឹះស្ថានឧត្តមសិក្សាឯកជន ត្រូវមានលក្ខណសម្បត្តិ ដូចខាងក្រោម ÷

ក. សាកលវិទ្យាធិការ និងនាយកត្រូវមាន ÷

- សញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាជាន់ខ្ពស់ឡើងទៅ ដែលចេញដោយគ្រឹះស្ថានឧត្តមសិក្សា ដែល

មានការទទួលស្គាល់ ដោយរដ្ឋាភិបាល ឬដោយស្ថាប័នទទួលស្គាល់គុណភាពអប់រំ នៅក្នុងសាមីប្រទេស

- បទពិសោធន៍យ៉ាងតិចប្រាំ (០៥) ឆ្នាំ ក្នុងផ្នែកឧត្តមសិក្សា និង/ឬ ក្នុងផ្នែកគ្រប់គ្រង
- សីលធម៌ល្អ និងមិនមានជាប់ពាក់ព័ន្ធនឹង បទល្មើសផ្សេងៗ ។

ខ. ព្រឹទ្ធបុរស និងប្រធានដេប៉ាតឺម៉ង់ត្រូវមាន ÷

- សញ្ញាបត្រចាប់ពីថ្នាក់បរិញ្ញាជាន់ខ្ពស់ឡើងទៅ ដែលចេញដោយគ្រឹះស្ថានឧត្តមសិក្សា ដែលមានការទទួលស្គាល់ដោយរដ្ឋាភិបាល ឬដោយស្ថាប័នទទួលស្គាល់គុណភាពអប់រំ នៅក្នុងសាមីប្រទេស
- បទពិសោធន៍យ៉ាងតិចបី (០៣) ឆ្នាំក្នុងការបង្រៀននៅឧត្តមសិក្សា និង/ឬក្នុងការគ្រប់គ្រង
- ជំនាញស្របទៅនឹងមហាវិទ្យាល័យ ឬដេប៉ាតឺម៉ង់ ដែលខ្លួនគ្រប់គ្រង
- សីលធម៌ល្អ និងមិនមានជាប់ពាក់ព័ន្ធនឹង បទល្មើសផ្សេងៗ ។

ប្រការ ១៦

ត្រូវរៀបចំតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងជាក់ស្តែងរបស់គ្រឹះស្ថានឧត្តមសិក្សាឱ្យបានច្បាស់លាស់ ដើម្បីធានាឱ្យបាននូវគុណភាព ប្រសិទ្ធភាព និងតម្លាភាពនៃការបណ្តុះបណ្តាល និងការគ្រប់គ្រង ។ ការកំណត់តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធគ្រប់គ្រងនេះ ត្រូវស្របតាមលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួងអប់រំ យុវជន និងកីឡា ។

ប្រការ ១៧

ត្រូវមានលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងបទដ្ឋាននានា ដើម្បីធានាដល់ដំណើរការ នៃការគ្រប់គ្រង និងការប្រព្រឹត្តទៅ របស់គ្រឹះស្ថានឧត្តមសិក្សា ។ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងបទដ្ឋាន ទាំងនោះរួមមាន ÷

- លក្ខន្តិកៈរបស់គ្រឹះស្ថានឧត្តមសិក្សា
- បទបញ្ជាផ្ទៃក្នុង សម្រាប់ក្រុមប្រឹក្សាភិបាល
- បទបញ្ជាផ្ទៃក្នុង សម្រាប់បុគ្គលិក និងសាស្ត្រាចារ្យ
- បទបញ្ជាផ្ទៃក្នុង សម្រាប់និស្សិត និង
- បទបញ្ជាផ្ទៃក្នុង និងបទដ្ឋានផ្សេងទៀត ស្របតាមតម្រូវការ នៃគ្រឹះស្ថានឧត្តមសិក្សា ។

លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងបទដ្ឋានទាំងនោះ ត្រូវស្របតាមលិខិតបទដ្ឋានគតិយុត្ត របស់ក្រសួងអប់រំ យុវជន និងកីឡា ។

## ផ្នែកទី ៥
## កម្មវិធីសិក្សា និងការបង្រៀន

ប្រការ ១៨

ត្រូវមានគណៈកម្មការបច្ចេកទេស និងគោលការណ៍ច្បាស់លាស់ សម្រាប់ការអភិវឌ្ឍកម្មវិធីសិក្សា នៃគ្រឹះស្ថានឧត្តមសិក្សា ។

ប្រការ ១៩

ការអភិវឌ្ឍកម្មវិធីសិក្សា ត្រូវស្របទៅនឹងបេសកកម្ម នៃគ្រឹះស្ថានឧត្តមសិក្សា និងសេចក្ដីសម្រេចលេខ ០៤/០៤ គ.ទ.ក.សសរ. ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្ដីពីការអនុវត្តកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត និងការផ្ទេរក្រេឌីត របស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ។

ប្រការ ២០

កម្មវិធីសិក្សាត្រូវមានគោលបំណង ការពិពណ៌នា និងរចនាសម្ព័ន្ធរួមនៃមុខវិជ្ជានីមួយៗ ។ មុខវិជ្ជានីមួយៗ នៃកម្មវិធីសិក្សា ត្រូវមានគោលបំណង ការពិពណ៌នាអំពីមុខវិជ្ជា និងចំនួនក្រេឌីត ។

ប្រការ ២១

ក្នុងកម្មវិធីសិក្សា ត្រូវបញ្ចូលមុខវិជ្ជាបន្ថែមដូចជា កុំព្យូទ័រ និងភាសាបរទេសណាមួយ ។ មុខវិជ្ជានីមួយៗ នៃកម្មវិធីសិក្សា ត្រូវមានគ្រូបង្រៀនគ្រប់គ្រាន់ដែលមានបច្ចេកទេសសម្រាប់មហាវិទ្យាល័យនីមួយៗ និងសៀវភៅសិក្សាគោល និងឯកសារពិគ្រោះផ្សេងទៀត ។ កម្មវិធីសិក្សាគ្រប់កម្រិត នៃគ្រឹះស្ថានឧត្តមសិក្សា ត្រូវមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា ។

ប្រការ ២២

គ្រឹះស្ថានឧត្តមសិក្សាដែលទើបបានទទួលអជ្ញាប័ណ្ណឱ្យប្រតិបត្តិការ និងមានការបណ្ដុះបណ្ដាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន មិនត្រូវបានអនុញ្ញាតឱ្យជ្រើសរើសនិស្សិតចូលសិក្សាក្រៅពីថ្នាក់ឆ្នាំសិក្សាមូលដ្ឋានឡើយ នៅក្នុងឆ្នាំសិក្សាដែលដំណើរការដំបូង ។

វិទ្យាស្ថាន ដែលទើបបានទទួល អជ្ញាប័ណ្ណឱ្យប្រតិបត្តិការ និងមិនមាន ការបណ្ដុះបណ្ដាលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន អាចធ្វើការជ្រើសរើសនិស្សិត ដែលមានវិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ឬវិញ្ញាបនបត្រសមមូលឱ្យចូលរៀនឆ្នាំទី២ ថ្នាក់បរិញ្ញាបត្រ ប៉ុន្តែមិនអនុញ្ញាតឱ្យជ្រើសរើសនិស្សិតចូលរៀនថ្នាក់ឆ្នាំទី៣ ឬទី៤ បានឡើយ នៅក្នុងឆ្នាំសិក្សា ដែលដំណើរការដំបូង ។

ប្រការ ២៣

គ្រឹះស្ថានឧត្តមសិក្សា អាចស្នើសុំការបណ្ដុះបណ្ដាល ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬថ្នាក់បណ្ឌិតបាន លុះត្រាតែគ្រឹះស្ថានឧត្តមសិក្សានោះ មាននិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រយ៉ាងតិចមួយជំនាន់ ឬថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់យ៉ាងតិចមួយជំនាន់ និងត្រូវមានរបាយការណ៍ដែលបង្ហាញពីភាពរឹងមាំ និងការរីកចំរើនរបស់គ្រឹះស្ថានឧត្តមសិក្សានោះ ។

## ផ្នែកទី ៦

## បុគ្គលិករដ្ឋបាល និងគ្រូបង្រៀន

ប្រការ ២៤

គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានលក្ខណវិនិច្ឆ័យ និងគោលការណ៍សម្រាប់ការជ្រើសរើស និងការអភិវឌ្ឍបុគ្គលិករដ្ឋបាល និងគ្រូបង្រៀន ស្របតាមច្បាប់ ដែលមានជាធរមាន ។

## ប្រការ ២៥

គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានគ្រូបង្រៀនពេញម៉ោងយ៉ាងតិចម្ភៃប្រាំ (២៥) ភាគរយ នៃចំនួនគ្រូបង្រៀនសរុប ។ គ្រូបង្រៀនពេញម៉ោងនៃគ្រឹះស្ថានឧត្តមសិក្សាមួយ ឬបុគ្គលិកពេញម៉ោងនៃអង្គភាពមួយ មិនអាចជា គ្រូបង្រៀនពេញម៉ោង នៃគ្រឹះស្ថានឧត្តមសិក្សាមួយផ្សេងទៀតបានទេ ។

---

## ប្រការ ២៦

ផលធៀបរវាងគ្រូបង្រៀន និងនិស្សិតនៅឧត្តមសិក្សា គឺ ១:៣០ ។ គ្រូបង្រៀននៅឧត្តមសិក្សា មិនអាចបង្រៀនលើសពី បី (០៣) មុខវិជ្ជា ក្នុងមួយឆមាស ។ មុខវិជ្ជាទាំងនោះ ត្រូវស្របទៅនឹងជំនាញរបស់ខ្លួន ។ ម៉ោងបង្រៀន អតិបរមា របស់គ្រូបង្រៀននៅឧត្តមសិក្សា គឺ ម្ភៃបួន (២៤) ម៉ោងក្នុងមួយសប្តាហ៍ ។

## ប្រការ ២៧

គ្រូបង្រៀននៅឧត្តមសិក្សា ត្រូវមានសញ្ញាបត្រខ្ពស់ជាងកម្មវិធី ដែលខ្លួនបង្រៀនមួយកម្រិត ។ ចំពោះគ្រូបង្រៀន ដែលមានសញ្ញាបត្រស្មើនឹងកម្មវិធីដែលខ្លួនបង្រៀន ត្រូវមានបទពិសោធន៍បង្រៀន និង/ឬបទពិសោធន៍វិជ្ជាជីវៈយ៉ាងតិចបី (០៣) ឆ្នាំ ។ ចំពោះអ្នកមានសញ្ញាបត្របរិញ្ញាពុំមានបទពិសោធន៍ អាចធ្វើជាគ្រូជំនួយបាន ។

## ប្រការ ២៨

គ្រឹះស្ថានឧត្តមសិក្សា ត្រូវបញ្ជូនបញ្ជីឈ្មោះគ្រូបង្រៀន មកនាយកដ្ឋានឧត្តមសិក្សានៃក្រសួង អប់រំ យុវជន និងកីឡា នៅចុងឆមាសទី១ នៃឆ្នាំសិក្សានីមួយៗ ។

# ផ្នែកទី ៧
# ទីតាំង អគារ និងមូលដ្ឋានសម្ភាររូបវ័ន្ត

## ប្រការ ២៩

ទីតាំង ត្រូវមាន បរិស្ថានសិក្សាល្អ និង មានផ្ទៃដីសមស្រប សម្រាប់អគារ បន្ទប់ពិសោធន៍ រោងជាង អាហារដ្ឋាន ចំណត និង ទីធ្លាកីឡា ។

## ប្រការ ៣០

ការសាងសង់ ត្រូវមានប្លង់មេ ប្លង់ផែនទី និង ប្លង់សាងសង់អគារ សម្រាប់បន្ទប់រៀន បន្ទប់រដ្ឋបាល បន្ទប់ពិសោធន៍ បណ្ណាល័យ អាហារដ្ឋាន អន្តេវាសិកដ្ឋាន បន្ទប់ហាត់កាយសម្ព័ន្ធ និងទីធ្លាកំសាន្តនានា ។ ប្លង់ផែនទី និង ប្លង់សាងសង់ ត្រូវបញ្ជាក់ឈ្មោះនីតិស្ថាបត្យករ និងវិស្វករ គម្រោងលម្អិតនៃថវិកា រយៈពេលសម្រាប់ការសាងសង់ និងគម្រោងលម្អិតនៃការរៀបចំប្រព័ន្ធទឹក អគ្គិសនី លូ ប្រព័ន្ធសុវត្ថិភាព និងប្រព័ន្ធផ្សេងទៀត ទាក់ទងទីតាំង និង អគារ ។

## ប្រការ ៣១

គ្រឹះស្ថានឧត្តមសិក្សា ត្រូវមាន អគារ បន្ទប់រៀន បន្ទប់រដ្ឋបាល បន្ទប់ប្រជុំ បណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់ពិសោធន៍ បន្ទប់សាស្ត្រាចារ្យ បន្ទប់អនាម័យ ព្រមទាំងទឹក និងភ្លើងអគ្គិសនីគ្រប់គ្រាន់ ដើម្បីឆ្លើយតប ទៅនឹង

បេសកកម្ម និងផែនការជ្រើសរើសនិស្សិត របស់គ្រឹះស្ថានឧត្តមសិក្សា ។ អគារសិក្សា ត្រូវបែងចែកឱ្យបានច្បាស់ សម្រាប់មហាវិទ្យាល័យ និង/ឬដេប៉ាតឺម៉ង់ ។ អគារ និង បន្ទប់ទាំងនោះ ត្រូវស្របទៅនឹង គោលការណ៍គរុកោសល្យ គឺ មានពន្លឺ និងខ្យល់អាកាសគ្រប់គ្រាន់ គ្មានសម្លេងរំខាន និងមានសុវត្ថិភាព ។

## ប្រការ ៣២

ផ្ទៃដី និង អគារ ត្រូវបញ្ជាក់ អំពីសិទ្ធិកាន់កាប់ និង ប្រើប្រាស់លើដីធ្លីនោះ ។ ក្នុងករណី ដីធ្លី ឬអគារជួលពីកម្មសិទ្ធិករដទៃ នោះរយៈពេលជួល ត្រូវមានយ៉ាងតិចបំផុតប្រាំ (០៥) ឆ្នាំ ។

## ប្រការ ៣៣

ត្រូវបំពាក់សម្ភារូបវត្ថុ និង ធនធានសិក្សា ឱ្យបានគ្រប់គ្រាន់ និងទំនើប ដើម្បីគាំទ្រដល់កម្មវិធី នៃការបណ្តុះបណ្តាល របស់គ្រឹះស្ថានឧត្តមសិក្សា ។

## ប្រការ ៣៤

ត្រូវរៀបចំបណ្ណាល័យ ឱ្យបានសមរម្យ ដើម្បីបម្រើឱ្យការសិក្សា និងការស្រាវជ្រាវ របស់និស្សិត និងសាស្ត្រាចារ្យ ។ បណ្ណាល័យ ត្រូវ ÷

- មានកន្លែងសម្រាប់រក្សា និងរៀបចំសៀវភៅ និងឯកសារសិក្សានានា
- មានកន្លែង ឬបន្ទប់សម្រាប់បុគ្គលិកបណ្ណាល័យ
- មានកន្លែងសម្រាប់អង្គុយអានឱ្យបានសមរម្យ ស្របនឹងបរិមាណនិស្សិត
- មានសង្ហារឹម និងសម្ភារៈផ្សេងទៀត បម្រើឱ្យសេចក្តីត្រូវការ នៃបណ្ណាល័យ
- មានបណ្ណារក្សមួយ (០១) នាក់យ៉ាងតិច ដែលមានសញ្ញាបត្រទាបបំផុតត្រឹមបរិញ្ញាបត្រ និងមានការបណ្តុះបណ្តាលផ្នែកបណ្ណាល័យ និងបុគ្គលិកជំនួយការយ៉ាងតិចពីរ (០២) នាក់ ដែលមានសញ្ញាបត្រទាបបំផុតត្រឹមបរិញ្ញាបត្ររង
- មានប្រព័ន្ធដែលមានការទទួលស្គាល់ជាសាកល សម្រាប់ការរៀបចំសៀវភៅ និងឯកសារសិក្សា
- មានបទបញ្ជាផ្ទៃក្នុង សម្រាប់បណ្ណាល័យ
- បើកទ្វារបម្រើសេវា យ៉ាងតិចបំផុតស្មើនឹង ម៉ោងសិក្សាប្រចាំថ្ងៃ
- តម្កល់ទុកសៀវភៅគោល (Text Books) យ៉ាងតិច ពីរ(០២) ចំណងជើងផ្សេងគ្នាក្នុងមុខវិជ្ជាមួយ ។ ក្នុងចំណងជើងនីមួយៗ ត្រូវមានសៀវភៅយ៉ាងតិចប្រាំ (០៥) ក្បាល ។ សៀវភៅទាំងនោះ ត្រូវមានអាយុតិចជាងដប់ (១០) ឆ្នាំ
- មានទស្សនាវដ្តី ព្រឹត្តប័ត្រព័ត៌មាន កាសែត និងឯកសារសិក្សាផ្សេងទៀត ដែលមួយមុខៗ ត្រូវមានចំនួនយ៉ាងតិចពីរ (២) ច្បាប់
- មានកម្មវិធីបង្រៀននិស្សិត ឱ្យចេះប្រើប្រាស់បណ្ណាល័យ ប្រកបដោយប្រសិទ្ធភាព
- មានម៉ាស៊ីនថតចម្លង សម្រាប់ការប្រើប្រាស់របស់និស្សិត និងសាស្ត្រាចារ្យ ។

ប្រការ ៣៥

ត្រូវបំពាក់អ៊ិនធើណិត និងកុំព្យូទ័រ សម្រាប់ការប្រើប្រាស់របស់និស្សិត និងសាស្ត្រាចារ្យ ។ ផលធៀបរវាងចំនួនកុំព្យូទ័រ និងនិស្សិតគឺ ១:៤ សម្រាប់ជំនាញដែលពាក់ព័ន្ធនឹងកុំព្យូទ័រ ។ ចំពោះជំនាញ ដែលមិនពាក់ព័ន្ធនឹងកុំព្យូទ័រជាមូលដ្ឋាន គ្រឹះស្ថានឧត្តមសិក្សា ត្រូវរៀបចំប្រព័ន្ធកុំព្យូទ័រ សមស្របតាមកម្មវិធីនិងកំណើនចំនួននិស្សិត ។

ប្រការ ៣៦

បន្ទប់កុំព្យូទ័រ ត្រូវបំពាក់ម៉ាស៊ីនព្រីន សម្រាប់ការប្រើប្រាស់របស់និស្សិត និងសាស្ត្រាចារ្យ ។ បន្ទប់ ដែលមានកុំព្យូទ័រម្ភៃ (២០) គ្រឿងចុះ ត្រូវបំពាក់ម៉ាស៊ីនព្រីនចំនួនមួយ ( ០១ ) និង ច្រើនជាងម្ភៃ ( ២០ ) គ្រឿង ត្រូវមានម៉ាស៊ីនព្រីនចំនួនពីរ ( ០២ ) ។ បន្ទប់មួយ ត្រូវមានកុំព្យូទ័រមិនលើសពីសាមសិប ( ៣០ ) គ្រឿង ។

## ផ្នែកទី ៨

## ផែនការយុទ្ធសាស្ត្រ និង ហិរញ្ញវត្ថុ

ប្រការ ៣៧

ត្រូវមាន ផែនការយុទ្ធសាស្ត្ររយៈពេលវែង និងមធ្យម និង ផែនការសកម្មភាពប្រចាំឆ្នាំ ដើម្បីអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សា ប្រកបដោយគុណភាព ប្រសិទ្ធភាព និង និរន្តរភាព ។ ការរៀបចំផែនការនេះ ត្រូវស្របទៅនឹងបេសសកកម្ម និង ធនធាន របស់គ្រឹះស្ថានឧត្តមសិក្សានោះ ។

ប្រការ ៣៨

ត្រូវមាន ផែនការហិរញ្ញវត្ថុរយៈពេលវែង និង គម្រោងថវិកាប្រចាំឆ្នាំ សម្រាប់ប្រតិបត្តិការ និងការអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សា ។

ប្រការ ៣៩

ជារៀងរាល់ឆ្នាំ នៅក្រោយដំណាច់ឆមាសទី ២ រយៈពេលពីរខែ គ្រឹះស្ថានឧត្តមសិក្សាត្រូវបញ្ជូន របាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន ចំនួន ០៣ ច្បាប់ មកក្រសួងអប់រំ យុវជន និងកីឡា ។

## ជំពូកទី ៣

## សំណុំឯកសារស្នើសុំបង្កើតគ្រឹះស្ថានឧត្តមសិក្សា

ប្រការ ៤០

ត្រូវដាក់សំណុំឯកសារស្នើសុំបង្កើតគ្រឹះស្ថានឧត្តមសិក្សាមកក្រសួងអប់រំ យុវជន និងកីឡា ចំនួនពីរច្បាប់ ។ សំណុំឯកសារស្នើសុំនេះ មានដូចខាងក្រោម ÷

- លិខិតស្នើសុំបង្កើតគ្រឹះស្ថានឧត្តមសិក្សា ផ្ញើជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដោយបញ្ជាក់ឱ្យបានច្បាស់លាស់ពីគោលបំណង កម្រិត និងមុខជំនាញបណ្តុះបណ្តាល

- ឯកសារអភិបាលកិច្ច និងការគ្រប់គ្រង ដោយភ្ជាប់មកជាមួយនូវ រចនាសម្ព័ន្ធគ្រប់គ្រង និងបទដ្ឋាន និងបទបញ្ជាផ្ទៃក្នុងដែលពាក់ព័ន្ធ
- ប្រវត្តិរូប របស់សាកលវិទ្យាធិការ នាយក ព្រឹទ្ធបុរស ប្រធានដេប៉ាតឺម៉ង់ និងប្រធានការិយាល័យ ដោយបញ្ជាក់ពីកម្រិតសញ្ញាបត្រ មុខជំនាញ និងបទពិសោធន៍ការងារ និងភ្ជាប់មកជាមួយនូវសន្លឹកសញ្ញាបត្រថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
- កម្មវិធីសិក្សាលម្អិត តាមកម្រិត និងមុខជំនាញ
- របាយការណ៍ ស្តីពីទីតាំង ផ្ទៃដី អគារ និង ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តផ្សេងទៀត
- របាយការណ៍ ស្តីពីមូលដ្ឋានសម្ភារដូចជា តុ កៅអី ក្តារខៀន កុំព្យូទ័រ សៀវភៅសិក្សា ឯកសារសិក្សា សម្ភារៈ និងឧបករណ៍ដទៃទៀត
- បញ្ជីរាយនាមបុគ្គលិក/សាស្ត្រាចារ្យ ដោយបញ្ជាក់ពីកម្រិតសញ្ញាបត្រ មុខជំនាញ និងបទពិសោធន៍ការងារ និងភ្ជាប់មកជាមួយនូវ ប្រវត្តិរូប សន្លឹកសញ្ញាបត្រថតចម្លងត្រឹមត្រូវតាមច្បាប់ដើម និងកិច្ចសន្យារវាងសាកលវិទ្យាធិការ ឬនាយក និងបុគ្គលិក/សាស្ត្រាចារ្យ
- ផែនការយុទ្ធសាស្ត្ររយៈពេលវែង និងមធ្យម និងផែនការសកម្មភាពប្រចាំឆ្នាំ របស់គ្រឹះស្ថានឧត្តមសិក្សា
- លក្ខខណ្ឌ និងវិធានការ ក្នុងការជ្រើសតាំងសាកលវិទ្យាធិការ ។

## ជំពូកទី ៤
## ការបង្កើតសាខា មហាវិទ្យាល័យថ្មី មុខជំនាញថ្មី និង/ឬ កម្រិតបណ្តុះបណ្តាលថ្មី

### ប្រការ ៤១

ការបង្កើតសាខា មហាវិទ្យាល័យថ្មី មុខជំនាញថ្មី និង/ឬ កម្រិតបណ្តុះបណ្តាលថ្មី ត្រូវគោរពតាមលក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យលម្អិត ដែលមានចែងក្នុងជំពូកទី ២ នៃប្រកាសនេះ ។

### ប្រការ ៤២

សំណុំឯកសារស្នើសុំបង្កើតសាខា មហាវិទ្យាល័យថ្មី មុខជំនាញថ្មី និង/ឬ កម្រិតបណ្តុះបណ្តាលថ្មីត្រូវរៀបចំឱ្យស្របទៅនឹងខ្លឹមសារ ដែលមានចែងក្នុងជំពូកទី ៣ នៃប្រកាសនេះ ។

## ជំពូកទី ៥
## ការពិនិត្យតាមដាន និងការវាយតម្លៃ

### ប្រការ ៤៣

គ្រឹះស្ថានឧត្តមសិក្សា ត្រូវមានការិយាល័យ ឬផ្នែកធានាគុណភាពអប់រំផ្ទៃក្នុង ដើម្បីធ្វើការស្វ័យវាយតម្លៃលើការអនុវត្ត នៃការបង្រៀន ការរៀន ការស្រាវជ្រាវ និងការអនុវត្តផ្សេងទៀត ស្របតាមបេសកកម្ម និង ទិសដៅដែលបានកំណត់ ។

### ប្រការ ៤៤

នាយកដ្ឋានជំនាញនៃក្រសួងអប់រំ យុវជន និងកីឡា ត្រូវមានយន្តការ នៃការចុះពិនិត្យតាមដាន និងការវាយ-

តម្លៃ លើការអនុវត្ត របស់គ្រឹះស្ថានឧត្តមសិក្សា ស្របតាមលក្ខណវិនិច្ឆ័យ ដែលមានចែងក្នុងប្រកាសនេះ ដើម្បីធានា និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអប់រំ នៅក្នុងគ្រឹះស្ថានឧត្តមសិក្សា ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**ប្រការ ៤៥**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤៦**

អគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានឧត្តមសិក្សា នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ អង្គភាពពាក់ព័ន្ធ និងគ្រឹះស្ថានឧត្តមសិក្សា ត្រូវអនុវត្តតាមប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី១២ ខែមករា ឆ្នាំ ២០០៧

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត កុល ផេង**

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
-គ្រប់អង្គភាពក្រោមឱវាទក្រសួង.អយក
-សមាគមគ្រឹះស្ថានឧត្តមសិក្សា
"ដើម្បីជ្រាបជាព័ត៌មាន"
-ដូចក្នុងប្រការ ៤៦ "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារ នា.ឧស